# អត្ថបទ ធម៌ទេសនា

ស្ដីអំពី

# “សតិបដ្ឋានសូត្រ”

ភិក្ខុ **កែវ-អ៊ុន ឬ សំអៀន**

**“ អភិញ្ញានសីលោ ”**

**វត្ត សម្ដេចព្រះមហាឃោសានន្ទ**

“សាខាមជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរអន្តរជាតិ”

ទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញ៉ា

សហរដ្ឋ អាមេរិក

សៅរ៍៨រោចចេត្រ,ឆ្នាំម្សាញ់បញ្ចស័ក ព.ស.២៥៥៦; ទី១៣ឧសភា គ.ស.២០១៣

សូមលោកអ្នក មេត្តានឹកឈ្មោះខ្ញុំ, ហើយឧទ្ទិសកុសលឲ្យដល់ខ្ញុំផង!

## អត្ថបទធម៌ ស្តីអំពី "សតិបដ្ឋានសូត្រ"

ធម៌សតិបដ្ឋានសូត្រនេះ ព្រះសម្ពុទ្ធទ្រង់ត្រាស់សម្តែងនៅដែន "កុរុឧត្តរកុរុទ្វីប"ខ្ញុំសំដែងនេះដោយយោលទៅតាមឧត្តមគតិជាគោលទស្សនៈរបស់ព្រះគ្រូសិរីសោភ័ណ គឹម-តូ នៅវត្តឧណ្ណាលោមរាជធានីភ្នំពេញផងដែរ។ ប៉ុន្តែមុននឹងចូលដល់សតិបដ្ឋានធម៌ ក៏គួរពុទ្ធបរិស័ទយើងយល់ថាព្រះពុទ្ធបរមគ្រូនៃយើងចាប់តាំងពីព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធឡើងក្នុងលោកមក! ព្រះអង្គមានព្រះហឫទ័យប្រកបដោយព្រះមហាករុណាប្រោសប្រទាន!ព្រះធម៌ទេសនាចំពោះសព្វសត្វទូទៅឥតរើសមុខអស់រយៈពេលចំនួន៤៥ឆ្នាំ, ដោយមានព្រះពុទ្ធបំណងចង់ឲ្យតែសព្វសត្វបានសម្រេចមគ្គផល ក្នុងពេលដែលកំពុងស្តាប់ព្រះធម៌ហ្នឹង!ឬស្តាប់ហើយយកទៅប្រព្រឹត្តប្រតិបត្តិតាមដើម្បីឆ្ពោះមុខត្រង់ទៅកាន់ព្រះនិព្វានតែម៉្យាងប៉ុណ្ណោះ,មិនមែនមានព្រះបំណងត្រឹមតែដឹកនាំសត្វឲ្យបានសុគតិគឺមនុស្ស ឬទេវតា,ឥន្ទព្រហ្មប៉ុណ្ណោះទេ,ពីព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ណាស់នូវភពទាំងពួងដែលព្រះអង្គធ្លាប់បានកើត-ស្លាប់ៗដោយផ្ទាល់ព្រះអង្គមក,អស់កាលជាអនេកជាតិមកហើយ,ព្រមទាំងទ្រង់ឈ្វេងយល់ដោយព្រះបញ្ញាញាណរបស់ព្រះអង្គផងទៀតថាៈ ភពទាំង៣ សឹងពោរពេញដោយគំនរ ភ្លើងទុក្ខភ្លើងកិលេស! កំពុងឆេះរោលរាលដុតកំដៅពពួកសត្វ! ឲ្យក្តៅក្រហល់ក្រហាយអន្ទះអន្ទែង!ជានិច្ច, នេះហើយដែលព្រះអង្គទ្រង់ព្រះនាមថាៈ "លោកវិទូ"នោះ។ ប៉ុន្តែពពួកសត្វនៅលើពិភពលោកទាំងមូលនេះ ដែលត្រូវអំណាចអវិជ្ជាដឹកមុខ ឬបិទបាំងមុខមិនឲ្យឃើញសេចក្តីពិត!, ក៏បែរជាសំគាល់ថាៈ ការកើតនៅក្នុងភព!ជាការសុខស្រួលទៅវិញ!!។ ដែលសំគាល់ថាៈ សុខស្រួលនោះ,តើសុខស្រួលយ៉ាងម៉េច? ឆ្លើយថាៈដែលសំគាល់ថាសុខស្រួលនោះ, ដោយគិតថានឹងបានធ្វើជាស្តេច, ធ្វើជាប្រធានាធិបតី,ធ្វើជានាយករដ្ឋមន្រ្តី, ជាសេដ្ឋីជាគហបតី, ជាអ្នកមាន, ដូច្នេះជាដើម..។

ដោយមិនបានដឹងច្បាស់ថាៈបន្តិចទៀតហ្នឹង!, ខ្លួននឹងត្រូវស្លាប់ចោល
របស់ទាំងអស់ហ្នឹងអស់ទាំងអស់គ្នាទៅហើយ!។ មិនមាននរណាម្នាក់
អាចយកបុណ្យសក្តិច្រងេងច្រងាងអ្វីទៅជាមួយផងបានទេ!ទាំងឡាន
វិឡា,មាស,ពេជ្រ, អ្វីៗផ្សេងៗទៀតក៏ត្រូវស្លាប់ចោលទាំងអស់។ ដូច្នេះ
បានជាព្រះពុទ្ធប្រៀបប្រដូច អ្នកទាំងអស់នេះថាៈដូចជាសត្វ មមាច!,
ធម្មតាសត្វមមាច!តែកាលណាវាក្រឡេកឃើញពន្លឺភ្លើងក្នុងពេលរាត្រី,
វាស្មានថាៈជារបស់ត្រជាក់ត្រជំសុខសប្បាយ ឬស្មានថាជាចំណី!ក៏នាំ
គ្នាហើរទៅចោមរោមផ្លែលក្រវែលលេងប្រឡែងពទ្ធ័ក្រឡឹងជុំវិញនាយ
អាយ,ដោយសេចក្តីល្ងង់,វង្វេងដោយមិនមានធម្មសញ្ញា,មិនយូរប៉ុន្មាន
ក៏ដល់នូវសេចក្តីវិនាសស្លាប់ដោយសារភ្លើងនោះស្ទើរតែទាំងអស់!!។
សេចក្តីនេះមានឧបមាយ៉ាងណាមិញ?ពួកមនុស្សទាំងឡាយនៅលើជុំ
ពិភពលោកនេះដែលត្រូវអវិជ្ជាបិទបាំងក៏សំគាល់ឃើញសម្បត្តិមនុស្ស
សម្បត្តិទេវតាថាៈសម្បត្តិទាំងអស់នោះជារបស់វិសេសត្រជាក់ត្រជុំប្រ-
កបដោយសេចក្តីសុខស្រួលទៀងទាត់មិនប្រែប្រួលម្ល៉ោះហើយក៏ច្រើន
តែនាំគ្នាបំពេញកុសលផ្សេងៗចំពោះតែខាង“វដ្តគាមិកុសល”គឺកុសល
ដែលឲ្យធ្វើដំណើរវិលវល់នៅតែក្នុងភពហ្នឹង!ព្រោះតែប្រាថ្នានូវសម្បត្តិ
ទាំងអស់នោះឯង! ដោយមិនបានដឹងតាមសេចក្តីពិតថាៈ សម្បត្តិទាំង
អស់នោះឯង វារមែងចងក្រៀកនូវបុគ្គលជាម្ចាស់នោះៗឲ្យជាប់នៅក្នុង
ភព! ហើយឆេះរោលរាលដោយភ្លើងទុក្ខភ្លើងកិលេសបន្តទៅទៀត,ធ្វើ
ឲ្យវិលវល់កើតស្លាប់ៗទទួលរងទុក្ខវេទនានៅក្នុងវដ្តៈរឿយៗរកទីបំផុត
គ្មាន!,ជួនកាលក៏ឈ្លក់វង្វេងស្រវឹងនឹងទ្រព្យសម្បត្តិបុណ្យសក្តិផ្សេងៗ
ហើយខ្លះបែរជាប្រព្រឹត្តធ្វើអំពើបាបអាក្រក់ផ្សេងៗមានសម្លាប់គេ,លួច
គេជាដើម, រួចអំពើបាបទាំងនោះវាជាកម្មបច្ច័យចាត់ចែងជាតិកំណើត
របស់មនុស្សនោះៗឲ្យថយចុះពីកំណើតមនុស្ស, ពីទេវតា,ឲ្យទៅជាកំ
ណើតក្នុងអបាយទាំងឡាយ,មានតិរច្ឆានជាដើមក៏មាន។ន័យត្រង់នេះ

សូមសាធុជនទាំងឡាយយល់ឲ្យច្បាស់ថាៈ ព្រះពុទ្ធមិនបង្ខំសត្វណាមួយថាត្រូវតែប្រតិបត្តិផ្លូវទៅកាន់ព្រះនិព្វានដោយដាច់ខាតនោះទេតី សត្វណាចង់ប្រតិបត្តិឲ្យបានកើតជាមនុស្សជាទេវតា, ជាឥន្ទព្រហ្ម,ក៏តាមប្រាថ្នាចុះ!ព្រះអង្គបារម្ភខ្លាចក្រែងតែមនុស្សខ្លះវាស្រវឹងឈ្លក់នឹងទ្រព្យសម្បត្តិស្រវឹងនឹងបុណ្យសក្តិស្រវឹងនឹងអំណាចខ្លាំងពេកទៅមិនខំធ្វើអំពើល្អគឺបុណ្យ! ដើម្បីរក្សានូវកំណើតរបស់ខ្លួនឲ្យស្ថិតនៅតែជាមនុស្ស,នៅតែជាទេវតាដដែលនោះ,រួចបែរទៅជាប្រព្រឹត្តធ្វើអំពើបាបមានសំឡាប់គេ,លួចទ្រព្យគេ,ជាដើមទៅវិញនោះ!ឯអំពើនោះៗវាជាកម្មបច្ច័យឬជាវិបាកបច្ច័យអាចចាត់ចែងឲ្យជាតិកំណើតរបស់មនុស្សអ្នកប្រព្រឹត្តធ្វើនោះឲ្យប្រែថយចុះពីមនុស្ស!ទៅជាកំណើតក្នុងអបាយមានតិរច្ឆានជាដើមទៅវិញនោះ! ហើយកំណើតនោះៗឯងមិនមានឱកាសនឹងបានធ្វើបុណ្យ-ទានអ្វីទេ!។ នែ! ព្រះពុទ្ធ! ព្រះអង្គបារម្ភខ្លាចក្រែងតែមនុស្សនោះៗវាវង្វេងអញ្ចឹង,ម្យ៉ាងទៀតលោកប្រដូចអ្នកទាំងនោះថាៈដូចជាមនុស្សខ្វាក់, ជាធម្មតាមនុស្សខ្វាក់ធ្វើដំណើរទៅណាមកណា,បើមិនមានគេជួយដឹកដៃផងទេ,តែងដើរត្រូវផ្លូវខ្លះខុសផ្លូវខ្លះ,យ៉ាងណាមិញ ?ឯពួកមនុស្សដែលប្រកបដោយអវិជ្ជាបិទបាំងមិនដឹងច្បាស់នូវកងទុក្ខទាំងពួង,ព្រោះការអន្ទោលទៅមកនៅក្នុងវដ្តៈបើមិនមានអ្នកប្រាជ្ញរាជបណ្ឌិតជួយដឹកនាំផងទេ, រមែងប្រារព្ធធ្វើនូវបុញ្ញាភិ-សង្ខារខ្លះ(ផ្នែកខាងបុណ្យ)ធ្វើនូវអបុញ្ញាភិសង្ខារខ្លះ(ផ្នែកខាងបាប)ឬធ្វើនូវអានេញ្ជាភិសង្ខារខ្លះ(ផ្នែកខាងឈានតែដែលនៅមានចិត្តវិប្ប-ល្លាស់ដោយទិដ្ឋិមានសស្សតទិដ្ឋិជាដើម)ក៏ដូច្នោះដែរ។គឺធ្វើអំពើកម្មហ្នឹងវាលាយបុណ្យខ្លះ,លាយបាបខ្លះ,អញ្ចឹងទៅ។ពួកមនុស្សទាំងនោះបើទុកជាធ្វើនូវបុញ្ញាភិសង្ខារគឺការតាក់តែងបុណ្យណាមួយដោយកាយវាចា,ចិត្តបុណ្យនោះឯងរមែងលាយឡំដោយទោសច្រើនប្រការ,ព្រោះអ្វី? ព្រោះប្រាថ្នាសម្បត្តិក្នុងបរលោកជាមនុស្សឬជាទេវតា,ណាមួយក្តី,

ប៉ុន្តែព្រះពុទ្ធពុំដែលសំដែងសរសើរចំពោះកំណើតរបស់សត្វដែលទៅ
កើតជាមនុស្សឬជាទេវតាឬជាឥន្ទព្រហ្មក្តី ថាជាកំណើតប្រកបដោយ
សុខផុតចាកទុក្ខទាំងពួងឡើយ!,ព្រោះព្រះអង្គជ្រាបច្បាស់ណាស់ថាៈ
បើជាតិកំណើតរបស់សត្វទាំងឡាយនៅតែមានដរាបណា?ក្តីទុក្ខទាំង
ឡាយ!មានជាតិទុក្ខជាដើមក៏នៅមានដរាបនោះដែរ! ។ ព្រះពុទ្ធទ្រង់
ត្រាស់សរសើរចំពោះតែព្រះនិព្វាន១គត់ថាជាធម្មជាតិអាចធ្វើសត្វទាំង
ឡាយឲ្យរលត់ផុតចាកទុក្ខគ្រប់ប្រការបានដូចមានព្រះពុទ្ធដីកានិរុជ្ឈន្តិ
តេសំ វូបសមោសុខោលុះតែរលត់នូវសង្ខារទាំងឡាយនោះអស់ហើយ
ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង!។ឯចំណែកខាងបុគ្គលដែលប្រកប
ដោយវិជ្ជាគឺសំដៅយកមនុស្សណាដែលលះនូវអវិជ្ជាបាន! គឺជាអរិយ-
បុគ្គលៗលោករមែងមានការយល់ឃើញថាៈការកើតជាមនុស្សក្តី,ឬជា
ទេវតាក្តី,ឥន្ទព្រហ្មក្តី,ដោយអំណាចនៃកាមាវចរកុសល,រូបាវចរកុសល
ណាមួយក្តី,ក៏គង់មិនរួចផុតចាកទុក្ខទាំងពួងបានឡើយ,ថែមទាំងយល់
ឃើញទៀតថាៈបើជាតិមិនទាន់អស់ទេ,ទុក្ខក៏មិនទាន់អស់ដែរ!ពីព្រោះ
កំណើតរបស់សព្វសត្វទាំងឡាយ!ដែលកើតក្នុងភពថោកទាបនិងភព
ឧត្តមនោះៗដោយអំណាចនៃកុសលាកុសលកម្ម,គឺសុទ្ធតែជាកំណើត
នៅមានការប្រែប្រួលមិនទៀងទាត់,កាលបើអស់អំណាចនៃកុសលា-
កុសលកម្មនោះៗហើយ,សត្វទាំងឡាយនោះៗ!ត្រូវតែវិលត្រឡប់មក
រកភពថ្មីវិញជាធម្មតា។រួចការធ្វើដំណើរវិលត្រឡប់ចុះវិលត្រឡប់ឡើង
នៅក្នុងវដ្តៈដោយអំណាចនៃផលបុណ្យនិងផលបាបដឹកនាំដូច្នេះ,តើទី
បំផុតនៃសេចក្តីទុក្ខរបស់សត្វនៅឯណា?។ ព្រះអរិយបុគ្គលលោកគិត
ដូច្នេះឯង! បុគ្គលដែលប្រកបដោយវិជ្ជាជាអរិយបុគ្គល,បើយល់ឃើញ
ដូច្នេះហើយលោកតែងមានសេចក្តីនឿយណាយធុញទ្រាន់នូវកំណើត
ដែលកើតរឿយៗក្នុងវដ្តៈនេះ,លោកក៏តែងត្រិះរិះរកឧបាយដើម្បីរំដោះ
ខ្លួនគេចចេញឲ្យរួចផុតស្រឡះចាកអំពីភពទាំង៣,ដោយការខំប្រឹងបំ-

ពេញកុសលផ្សេងៗចំពោះតែខាង“វិវដ្តគាមិកុសល”គឺកុសលដែលធ្វើ ដំណើរឆ្ពោះទៅកាន់ទីប្រាសចាកវដ្តៈគឺព្រះនិព្វាន។បុគ្គលនោះៗកាល បើធ្វើកុសលណាមួយដោយកាយវាចាចិត្តមានការឲ្យទានជាដើមរមែង តាំងចិត្តដើម្បីពង្រីងបង្អស់នូវពួកកិលេសទាំងឡាយមានលោភជាដើម ឲ្យរីងស្ងួតអស់ពីសន្តានចិត្តឈមមុខឆ្ពោះទៅរកព្រះនិព្វានជាអារម្មណ៍ តែម្យ៉ាងប៉ុណ្ណោះ!កុសលរបស់បុគ្គលនោះហៅថា“វិវដ្តគាមិកុសល” គឺ កុសលឆ្ពោះទៅរកព្រះនិព្វាននោះឯង។ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធ សម្តែងដើម្បីឆ្ពោះទៅកាន់ព្រះនិព្វាននោះមានច្រើនជាអនេក,ប៉ុន្តែក្នុង ទីខ្លះព្រះអង្គសំដែងសំដៅយកវិបស្សនាតែម្យ៉ាង,ទីខ្លះសំដៅយកសមថៈនិងវិបស្សនា,ទីខ្លះសំដៅយកអដ្ឋង្គិកមគ្គគឺមគ្គផ្លូវប្រកបដោយអង្គ៨ ប្រការ,ទីខ្លះសំដៅយកត្រៃសិក្ខាៈសីល.សមាធិ.បញ្ញា,ទីខ្លះសំដៅយក ពោធិបក្ខិយធម៌ទាំង៣៧,មានសតិបដ្ឋាន៤និងសម្មប្បធាន៤ជាដើម, រីឯក្នុងទីនេះព្រះសម្មាសម្ពុទ្ធព្រះអង្គសំដៅយកចំពោះ“សតិបដ្ឋាន៤” តែម្យ៉ាងប៉ុណ្ណោះ។តទៅសតិបដ្ឋាន៤ សាធុសប្បុរសទាំងឡាយ!សូម ស្តាប់ឲ្យបានច្បាស់មែនទែន,ពាក្យថាសតិបដ្ឋានប្រែៈការដំកល់ឬការ ផ្ចង់សតិស្មារតី,សតិប្រែថាធម្មជាតិជាគ្រឿងរលឹកនឹកឃើញ, ជាគុណ ជាតិមានប្រយោជន៍សំខាន់ណាស់ចំពោះកាតព្វកិច្ចទូទៅទាំងក្នុងគតិ លោកទាំងក្នុងគតិធម៌,មនុស្សនៅលើពិភពលោកនេះទាំងមូលទោះបី ធ្វើការងារអ្វីដោយកាយក្តី, ទោះនិយាយអ្វីដោយវាចាក្តី, ឬទោះគិតអ្វី ដោយចិត្តក្តីត្រូវមានសតិតាំងនៅមាំជាប្រមុខជាដរាបទើបការងារនោះ ៗមិនភ្លាត់ខុស,អាចញ៉ាំងប្រយោជន៍ឲ្យសម្រេចដ៏ល្អប្រសើរ។ មនុស្ស ខ្លះដែលធ្វើការងារអ្វីមួយដោយកាយក្តីវាចាក្តីចិត្តក្តី,ហើយច្រើនតែជ្រលួសជ្រួសភ្លាត់ខុសនាំឲ្យអន្តរាយមិនបានសម្រេចប្រយោជន៍នោះៗក៏ ព្រោះតែមនុស្សនោះមិនបានដំកល់សតិស្មារតីឲ្យតាំងនៅមាំបណ្តោយ សតិឲ្យរាយមាយទាសទៅរកអារម្មណ៍ផ្សេងៗនោះឯង!។ចំណែកខាង

គតិធម៌វិញក៏រឹតតែត្រូវអាស្រ័យសតិជាប្រមុខណាស់ទៅទៀត, ព្រោះហេតុនោះបានជាព្រះពុទ្ធ,កាលដែលទ្រង់សំដែងធម៌ សតិបដ្ឋាន នេះព្រះអង្គឲ្យលើកយកសតិមកធ្វើជាប្រមុខគ្រប់អន្លើជាដាច់ខាតក្នុងការពិចារណាឬចំរើននូវព្រះធម៌ណាមួយ។នៅក្នុងទីនេះព្រះអង្គឲ្យពិចារណាអំពីព្រះធម៌សតិបដ្ឋាន៤ៈសតិបដ្ឋាន៤ជាផ្លូវដ៏បរិសុទ្ធស្អាត,យ៉ាងក្រៃលែង!សម្រាប់ឲ្យមនុស្សនៅលើពិភពលោកទាំងមូលប្រតិបត្តិឆ្ពោះទៅកាន់ព្រះនិព្វាន,ព្រោះហេតុនោះគួរបរិស័ទាំងឡាយទាំងពុទ្ធបរិស័ទក្តីទាំងមិនទាន់ជាពុទ្ធបរិស័ទក្តីគួរបង្អោនចិត្តឲ្យល្អសិក្សា.ស្តាប់.គោរពប្រតិបត្តិតាមសតិបដ្ឋានធម៌ដែលមានសេចក្តីដូចតទៅ,សម័យមួយនៅពេលដែលព្រះសម្មាសម្ពុទ្ធ,ស្តេចគង់នៅក្នុងដែនកុរុ, អាស្រ័យនៅកម្មាសធម្មនិគមនៃដែនកុរុ!ដោយហេតុថាជនានុជនទាំងអស់នៅដែននោះជាអ្នកបរិសុទ្ធ,មានចិត្តនឹងន,មានសតិតាំងនៅមាំជានិច្ច!អាចស្តាប់នូវធម៌សតិបដ្ឋានសូត្រ,ជាធម៌ល្អិតសុខុមជ្រាលជ្រៅបាន,ទើបព្រះអង្គសំដែងនៅទីនោះ!។ ក្នុងគម្ពីរសុមង្គលវិលាសិនីអដ្ឋកថាទីឃនិកាយមានសេចក្តីសំដែងសរសើរថាៈ ពួកបរិស័ទទាំង៤គឺៈភិក្ខុ, ភិក្ខុនី, ឧបាសក, ឧបាសិកា,ក្នុងដែនកុរុច្រើនតែជាអ្នកមានព្យាយាមមុតមាំណាស់,ចំរើនសតិបដ្ឋានរឿយៗ,ដោយហោចទៅ,សូម្បីពួកជនជាទាសកម្មករក៏តែងតែនាំគ្នានិយាយតែពាក្យដែលប្រកបដោយសតិបដ្ឋានធម៌ដែរ! ទោះបីក្នុងពេលដែលកំពុងធ្វើការងារអ្វីផ្សេងៗមាន,ដងទឹក,ពុះអុស,ឬក៏រវៃអំបោះជាដើម,ក៏មិនសូវនិយាយពាក្យឥតប្រយោជន៍ឡើយ!ឧទាហរណ៍ដូចជាបើស្ត្រីណាមួយមានគេសួរថា“នែ!នាង!ៗឯងបានធ្វើទុកក្នុងចិត្តនូវសតិបដ្ឋានណាមួយខ្លះទេ?ថ្ងៃនេះ?”បើនាងនោះឆ្លើយថាៈ“នាងខ្ញុំមិនបានធ្វើទុកក្នុងចិត្តនូវអ្វីបន្តិចបន្តួចទេថ្ងៃនេះ”ដូច្នេះគេនឹងតិះដៀលស្ត្រីនោះថា“នែនាង!ជីវិតនាងឯងជាជីវិតឥតប្រយោជន៍,បើទុកជានាងឯងកំពុងរស់នៅហ្នឹង!ក៏ដូចជាមនុស្សដែលស្លាប់បាត់ទៅហើយដែរ”៕

!រួចគេក៏ឲ្យឱវាទដល់ស្ត្រីនោះថា“ឥឡូវនាងឯងចូរកុំធ្វើយ៉ាងនេះតទៅទៀត”ហើយគេក៏បង្រៀនស្រីនោះឲ្យចេះសតិបដ្ឋានណាមួយតាមការគួរទៅ។ម្យ៉ាងទៀតបើស្ត្រីណាមួយដែលគេសួរដូច្នេះដែរ! ហើយនាងនិយាយថា“ថ្ងៃនេះនាងខ្ញុំបានធ្វើទុកក្នុងចិត្តនូវសតិបដ្ឋានឈ្មោះនេះៗ”យ៉ាងនេះវិញ, នោះគេក៏ឲ្យពរសព្វសាធុការដល់ស្ត្រីនោះថា“សាធុៗ! ជីវិតរបស់នាងជាជីវិតប្រសើរណាស់!មានប្រយោជន៍ណាស់!នាងឯងហៅពេញជាមនុស្សមានភ័ព្វ!,ព្រះសម្ពុទ្ធដែលបានត្រាស់ដឹងឡើងក្នុងលោកក៏ដើម្បីជាប្រយោជន៍ដល់នាងផងដែរ!។ = នែ!មនុស្សនៅដែនកុរុ គេតែងអប់រំមនុស្សរបស់គេឲ្យមានប្រយោជន៍សំរាប់ខ្លួននាងផ្ទាល់ផង,និងដល់សង្គមរបស់ពួកគេផងយ៉ាងនេះឯង!ឯក្នុងដែនកុរុនោះមិនមែនត្រឹមតែមនុស្សប៉ុណ្ណោះទេ!,ដែលបានធ្វើទុកក្នុងចិត្តនូវសតិបដ្ឋានសូម្បីសត្វតិរច្ឆានដែលរស់នៅអាស្រ័យជាមួយមនុស្សទាំងនោះ!,ក៏គេបង្រៀនឲ្យចេះនិយាយភាសាមនុស្សនិងបង្រៀនឲ្យចេះបរិកម្មនូវសតិបដ្ឋានខ្លះដែរ។ដូចមានរឿងនិទាន១ជាឧទាហរណ៍ថានៅដែនកុរុនោះមានអ្នករបាំម្នាក់!បានចាប់កូនសត្វសេក១យកទៅចិញ្ចឹម! ហើយបានបង្រៀនវាឲ្យចេះនិយាយភាសាមនុស្ស!។ ថ្ងៃមួយអ្នករបាំនោះបាននាំយកកូនសេកនោះទៅកាន់សំណាក់ភិក្ខុនី, លុះវេលាត្រឡប់មកវិញ ក៏ភ្លេចកូនសេកចោលនៅទីនោះ, ឯពួកសាមណេរីបានឃើញក៏ចាប់កូនសេកនោះយកទៅថែរក្សាទុក, រួចកំណត់ឲ្យឈ្មោះសេកនោះថា“ពុទ្ធរក្ខិត”។ ថ្ងៃមួយព្រះមហាថេរីបានឃើញកូនសេកនោះទំនៅពីខាងមុខក៏ហៅសួរថាៈនែ!ពុទ្ធរក្ខិត! ឯងមានធ្វើទុកក្នុងចិត្តនូវភាវនាអ្វីខ្លះទេថ្ងៃនេះ?,សេកទូលតបថាៈឱ!លោកម្ចាស់! ខ្ញុំមិនបានធ្វើទុកក្នុងចិត្តនូវអ្វីទេថ្ងៃនេះ!, ព្រះថេរីក៏ពោលថា“នែ!អាវុសោ!សេក! ឯងមកនៅក្នុងសំណាក់នៃបព្វជិតនេះ មិនគួរនៅដោយអត្តភាពឥតប្រយោជន៍ដូច្នេះទេ! ឯងគួរតែធ្វើបរិកម្មនូវធម៌ណាមួយកុំខាន,ប៉ុន្តែឯងមិនអាចបរិកម្មនូវធម៌

ដទៃៗបានទេ,ឯងចូរស្វាធ្យាយត្រឹមតែថា“អដ្ឋិៗ-ឆ្អឹង-ៗដូច្នេះចុះ”កូនសេកនោះក៏បានស្ថិតនៅក្នុងឱវាទនៃព្រះមហាថេរីយ៉ាងមុតមាំហើយខំប្រឹងប្រព្រឹត្តស្វាធ្យាយថាអដ្ឋិ-អដ្ឋិយ៉ាងនេះញាប់ស្ទើមិនដាច់ពីមាត់! ថ្ងៃមួយសេកនោះកំពុងតែទំហាលថ្ងៃនៅលើក្លោងទ្វារនាវេលាព្រឹក,ក៏ស្រាប់តែមានសត្វខ្លែង១ក្រឡេកឃើញ,ក៏បានឆាបចាប់យកកូនសេកនោះទៅ,កូនសេកនោះបានស្រែកយ៉ាងខ្លាំងថា“កិរិៗក្រិៗ,អដ្ឋិៗ”ពួកសាមណេរីបានឮបានឃើញ, ហើយក៏នាំគ្នាចាប់យកដុំដីគ្រវែងចោលទៅដោយស្រែកបង្អើលយ៉ាងសន្ធាប់ដ៏គិគកងរំពងធ្វើឲ្យខ្លែងនោះឯងស្លុតស្មារតីបានរបូតធ្លាក់កូនសេកនោះមកវិញ។ពួកសាមណេរីក៏បាននាំកូនសេកនោះទៅដាក់នៅពីមុខព្រះមហាថេរីៗក៏សួរថា:នៃពុទ្ធរក្ខិតៗ!កាលដែលសត្វស្លាបឆាបនាំឯងយកទៅនោះ,តើឯងមានបានគិតអ្វីដូចម្ដេចខ្លះទេ ?សេកឆ្លើយទូលថា“ទានម្ចាស់ខ្ញុំគ្មានគិតអ្វីដទៃទេខ្ញុំគិតតែយ៉ាងនេះថា“ឱ!គំនរឆ្អឹងមកនាំគំនរឆ្អឹងយកទៅរោយរាយទុកនៅទីណាអេះ!? ខ្ញុំគិតតែប៉ុណ្ណេះឯង!”។ព្រះមហាថេរីស្ដាប់ហើយក៏ឧទានឲ្យពរសព្វសាធុការថា“សាធុៗ!ពុទ្ធរក្ខិត!គំនិតនេះហើយនឹងជាបច្ច័យនាំឯងឲ្យអស់ភពទៅក្នុងអនាគតមិនខាន។សាធុសប្បុរសទាំងឡាយ! ក្នុងដែនកុរុនោះសូម្បីសត្វតិរច្ឆានក៏ចេះចំរើនសតិបដ្ឋានខ្លះដែរ,ដូចជារឿងសេកនេះឯង។នេះក៏ជាការសបញ្ជាក់ថាពួកអ្នកដែនកុរុមានសេចក្ដីចំរើនលូតលាស់ដោយប្រាជ្ញាស្មារតីដ៏ល្អិតសុខុមណាស់,ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធទ្រង់សំដែងធម៌ “សតិបដ្ឋានសូត្រ” នៅទីនោះ!។=ធម៌សតិបដ្ឋានសូត្រព្រះអង្គសំដែងថា:ម្នាលភិក្ខុទាំងឡាយ! ផ្លូវគឺសតិបដ្ឋាន៤នេះ!ជាផ្លូវមូលតែមួយប្រព្រឹត្តទៅដើម្បីសេចក្ដីស្អាតបរិសុទ្ធផូរផង់ដល់ចិត្តរបស់សត្វទាំងឡាយដែលមានចិត្តសៅហ្មងដោយមន្ទិលទាំងឡាយមានរាគៈជាដើម.ឲ្យជ្រះស្រឡះបាន។=ផ្លូវគឺសតិបដ្ឋាន៤នេះប្រព្រឹត្តទៅដើម្បីកន្លងបង់នូវសេចក្ដីសោកខ្សឹកខ្សួលរំជួល

ចិត្តទាំងឡាយ។=ផ្លូវ =ប្រព្រឹត្តទៅដើម្បីផុតរលត់នៃទុក្ខនិងទោមនស្ស ទាំងឡាយ ។ = ផ្លូវ = ប្រព្រឹត្តទៅដើម្បីដល់នូវអរិយមគ្គជាធម៌ស្រោចស្រង់សត្វ ។ = ផ្លូវ = ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន។ ព្រះសម្មាសម្ពុទ្ធស្តេចចង្អុលបង្ហាញនូវគុណសម្បត្តិឬអត្ថប្រយោជន៍នៃការគោរពប្រតិបត្តិតាមគន្លងសតិបដ្ឋានធម៌ដ៏ល្អប្រសើរនេះដូច្នេះឯង។ សតិបដ្ឋានធម៌មាន៤យ៉ាង,ទី១-កាយានុបស្សនាសតិបដ្ឋាន ការដំកល់ស្មារតីពិចារណានូវកាយក្នុងកាយ។២-វេទនានុបស្សនាសតិបដ្ឋានការដំកល់ស្មារតីពិចារណានូវវេទនា។ ទី៣-ចិត្តានុបស្សនាសតិបដ្ឋាន ការដំកល់សតិស្មារតីពិចារណានូវចិត្តក្នុង។ទី៤-ធម្មានុបស្សនាសតិបដ្ឋាន ការដំកល់សតិស្មារតីពិចារណានូវធម៌ក្នុងធម៌។ ក្នុងកិច្ចដែលពិចារណានូវសតិបដ្ឋានធម៌នេះ!ព្រះសម្មាសម្ពុទ្ធទ្រង់ប្រើព្រះពុទ្ធដីកាថាភិក្ខុគ្រប់អន្លើទាំងអស់,គឺប្រើបានទាំងអ្នកបួសទាំងគ្រហស្ថផង។ព្រោះពាក្យថា “ ភិក្ខុ”ប្រែថាអ្នកឃើញភ័យក្នុងសង្សារវដ្ត”។= ក្នុងសតិបដ្ឋានទី១ ព្រះអង្គត្រាស់សំដែងថា,កាយានុបស្សនាសតិបដ្ឋានប្រែៈភិក្ខុមានព្យាយាមដុតបំផ្លាញនូវកិលេសក្នុងភពទាំង៣ប្រកបដោយញាណគឺ សម្បជញ្ញៈ សេចក្តីដឹងច្បាស់!,ទាំងប្រកបដោយ សតិ ជាគ្រឿងកំណត់ពិចារណាឃើញនូវកាយក្នុងកាយរួចបន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ពាក្យថាៈលោកក្នុងទីនេះ,លោកសំដៅយករូបកាយរបស់មនុស្សយើងហ្នឹងឯង។ធម៌សតិបដ្ឋាននេះជាធម៌ល្អិតជ្រាលជ្រៅណាស់!យើងស្តាប់និងពិនិត្យមើលត្រង់ប្រយោគដែលពុទ្ធដីកាចែងថាៈ ភិក្ខុមានព្យាយាមដុតបំផ្លាញនូវកិលេសក្នុងភពទាំង៣, តែប៉ុណ្ណេះក៏ឃើញច្បាស់ ថាមិនមែនព្យាយាមល្មមៗធម្មតានោះបានទេ!គឺទាល់តែព្យាយាមថ្នាក់ឧក្រឹដ្ឋយ៉ាងម៉ឺងម៉ាត់បំផុតដល់ថ្នាក់ដុតបំផ្លាញឯណោះទើបបានបើមិនដូច្នោះទេពួកកិលេសទាំងឡាយវានឹងដុតបំផ្លាញរូបកាយយើងវិញជាមិនខានសូមលោកអ្នកសប្បុរសទាំងឡាយ! ពិចារណាលំអិតឡើងវិញនៅត្រង់

ប្រយោគថាៈ “ ភិក្ខុមានព្យាយាមដុតបំផ្លាញនូវកិលេសក្នុងភពទាំង៣ ប្រកបដោយញាណសម្បជញ្ញៈទាំងប្រកបដោយសតិជាគ្រឿងកំណត់ពិចារណាឲ្យឃើញនូវកាយក្នុងកាយ”។សួរៈតើការពិចារណានូវកាយក្នុងកាយ!ពិចារណាយ៉ាងម៉េច?ចម្លើយៈជាអត្ថានុរូបថាៈតើនៅក្នុងរូបកាយរបស់មនុស្សយើងទាំងអស់គ្នាហ្នឹង!មានអ្វីខ្លះ? គឺពិចារណាឲ្យទាល់តែឃើញច្បាស់ថាៈឱ!រូបកាយរបស់មនុស្សយើងគ្រប់គ្នាហ្នឹង,ជាទីប្រជុំចុះនៃវត្ថុមិនស្អាតសព្វយ៉ាងមានអាការៈ៣២ប្រការ ជាដើម! គឺៈ កេសាសក់,លោមារោម,នខាក្រចក,ទន្តាធ្មេញ,តចោស្បែក,មំសំសាច់ នហារូសរសៃ,អដ្ឋីឆ្អឹង,អដ្ឋិមិញ្ជំខួរក្នុងឆ្អឹង, វក្កំទាចដម្រងនោម,ហទយំ បេះដូង,យកនំថ្លើម,កិលោមកំវាវ,បិហកំក្រពះ, បប្ផាសំសួត, អន្តំពោះវៀនធំ, អន្តគុណំ ពោះវៀនតូច, ឧទរីយំអាហារថ្មី, ករីសំ អាហារចាស់, បិត្តំប្រមាត់,សេម្ហំស្លេស្ម៍,បុព្វោខ្ទុះ,លោហិតំឈាមសេទោញើស,មេទោខ្លាញ់ខាប់,អស្សុទឹកភ្នែក,វសាខ្លាញ់រាវ, ខេឡោទឹកមាត់, សិង្ឃាណិកាទឹកសម្បោរ,លសិកាទឹករំអិលមុត្តំទឹកម៉ូត្រ,មតកេមតឡុង្គំខួរក្នុងក្បាល ឥឡូវយើងពិនិត្យមើលអាការៈទាំង៣២ហ្នឹង, តើមានអាការៈណាមួយដែលមានខ្លឹមសារ? មានស្ថេរភាព, អាចតាំងនៅមាំដែលមិនប្រែប្រួលនោះ?បើនិយាយតាមផ្លូវបរមត្ថធម៌នោះ!នឹងឃើញថាវាប្រែប្រួលរាល់នាទី,រាល់វិនាទី។ឯបម្រែបម្រួលនៃសង្ខារលោកនេះ,យើងពុំអាចមើលដោយភ្នែកធម្មតានេះបានទេលុះតែយើងធ្វើការប្រៀបធៀបទើបស្រួលយល់គឺយើងយកនាឡិកាដៃមកពិនិត្យមើលទ្រនិចតូចរបស់វា,ដែលវាចង្អុលប្រាប់វិនាទី,យើងនឹងឃើញទ្រនិចតូចនោះវាដើរ“ច្រិកៗ!ច្រិកៗ!”ទៅមុខរហូត, រីឯពេលវេលាថ្ងៃនិងយប់ក៏វានាំជីវិតសង្ខាររបស់យើងទៅមុខឥតឈប់ឥតវិលត្រឡប់ក្រោយដែរ! រួចតើវានាំទៅណា? គឺនាំទៅកាន់ទីចាស់,ជរា,ព្យាធិ,និងមរណៈនោះឯង, កាលណាយើងពិចារណានូវអាការៈ៣២ប្រការ នៅក្នុងរូបកាយរបស់យើងរឿយៗទៅ, យូរ

ទៅយើងនឹងអាចមានសេចក្តីនឿយណាយធុញទ្រាន់ខ្លះៗទៅដែរ!រួច ពេលនោះ យើងនឹងអាចបន្ទោបង់នូវ អភិជ្ឈា និងទោមនស្ស ពីក្នុងរូប កាយរបស់យើងបានខ្លះៗហើយ, កុំឲ្យវាស្តុកនៅច្រើនពេក។ អភិជ្ឈា លោកសំដៅយកកាមច្ឆន្ទៈចំណង់ក្នុងកាមឬសេចក្តីត្រេកត្រអាលក្នុង កាម,ទោមនស្សលោកសំដៅយកព្យាបាទៈ ឬបដិឃៈសេចក្តីថ្នាំងថ្នាក់ ចិត្តចងគំនុំគុំគួន!ម្យ៉ាងទៀតព្រះពុទ្ធពោលថាៈភិក្ខុកាលណាឃើញរូប កាយរបស់ខ្លួនមិនមានវិកលវិការជាកាយបរិបូរណ៌!ដោយសុខភាពល្អ រមែងមានចិត្តត្រេកត្រអាល, ជាប់ជំពាក់ចិត្តចំពោះកាយសម្បទារបស់ ខ្លួនមួនមាំណាស់ចង់តែឲ្យកាយរបស់ខ្លួនសុខស្រួលប្រសើរៗជាងនេះ ទៀតរហូតទៅ! ផ្ទុយទៅវិញប្រសិនបើរូបកាយរបស់ខ្លួនដល់នូវក្តីវិបត្តិ ផ្សេងៗរមែងមានទោមនស្សតូចចិត្តឆ្អិតឆ្អន់ពន់ប្រមាណណាស់។ នេះ ជាធម្មតាចិត្តរបស់បុថុជ្ជន។ព្រោះហេតុនោះបានជាព្រះពុទ្ធទ្រង់ទូន្មាន ថាៈឲ្យពួកភិក្ខុពិចារណាឲ្យបានឃើញច្បាស់ថារូបកាយនេះជាអត្តភាព មិនមានខ្លឹមសារទេ រមែងធ្លាក់ចុះទៅក្នុងអនិច្ចលក្ខណធម៌ជាដើម! ជា លក្ខណៈ។ ព្រះពុទ្ធដីកាថាៈ បរិជិណ្ណមិទំ រូបំ រោគនិទ្ធំ បភង្គុណំ ភិជ្ជតិ បូតិ សន្ទេហោ មរណន្តំ ហិ ជីវិតំ  រូបកាយរបស់មនុស្សនៅលើដុំពិភព លោកទាំងមូលនេះ,តែងប្រែប្រួលចាស់គ្រាំគ្រាគ្រប់ៗគ្នា! ជារៀងរាល់ ម៉ោង.រាល់នាទី.រាល់វិនាទី,ជាលំនៅនៃរោគគ្រប់ជំពូកជារបស់ពុកផុយ មិនមានមាំមួនអ្វីទេ,រូបកាយនេះតែងបែកធ្លាយជាធម្មតា,កាលបើបែក ធ្លាយហើយជារបស់ស្អុយៗជាងអ្វីៗទាំងអស់,គួរខ្ពើមរអើមពេកណាស់ ព្រោះថាជីវិតរបស់មនុស្សសត្វត្រូវតែស្លាប់គ្រប់ៗគ្នានៅទីបំផុត។ដូច្នេះ យើងទាំងអស់គ្នា គួរតែដកចេញ- សេចក្តីប្រកួតប្រកាន់ចំពោះរូបកាយ នេះឲ្យបានច្រើនបំផុតកុំស្រវឹងកុំឈ្លក់វង្វេងនឹងសម្ផស្សសម្រស់ស្រស់ ត្រកាល,ដែលបណ្តាលមកពីគ្រឿងតុបតែងខាងក្រៅទាំងអម្បាលម៉ាន នោះថាជារបស់មានខ្លឹមសារទៀងទាត់ប្រាកដប្រជា,មិនប្រែប្រួលនោះ

ឲ្យសោះ! ព្រោះវាសុទ្ធតែជារបស់បោកបញ្ឆោតទេ! ជាសិប្បនិមិត្តសំរាប់បំភាន់ភ្នែករបស់បុថុជ្ជនតែម៉្យាងប៉ុណ្ណោះ! ប៉ុន្តែនិយាយយ៉ាងនេះមិនមែនមានន័យថាៈមិនឲ្យថែទាំសំអាតរូបកាយនោះទេ,ពីព្រោះព្រះពុទ្ធមានផែនការសព្វគ្រប់ឥតខ្វះចន្លោះក្នុងការរៀបចំរូបកាយនេះ ឲ្យសម្របសម្រួលទៅតាមក្បួនអនាម័យការពារកុំឲមានរោគគ្រប់ប្រការកើតមានឡើងដល់រូបកាយនោះ,ដូចមានព្រះពុទ្ធ ដំបូន្មានថាៈអរោគ្យ បរមាលាភាការមិនមានរោគជាលាភដ៏ប្រសើរក្រៃលែងប៉ុណ្ណោះជាដើម ប៉ុន្តែដែលព្រះអង្គបារម្ភហើយទូន្មាន,រួចទូន្មានទៀតនោះព្រោះព្រះអង្គមិនចង់ឃើញមនុស្សដែលមានសុខភាពល្អ, មានកាយសម្បទាល្អគ្រប់គ្រាន់,មានទ្រព្យសម្បត្តិស្តុកស្តម្ភ,មានបុណ្យសក្តិធំៗមានអំណាចខ្លាំងៗគ្រប់គ្រាន់ហើយហើយបែរជាយករបស់អស់ទាំងនោះទៅបៀតបៀនទៅសង្កត់សង្កិនទៅរឹបជាន់មនុស្សផងគ្នា,ដោយអំណាច,ដោយលោភចិត្តនិងមោហាចិត្តប្រព្រឹត្តដោយអយុត្តិធម៌រំលោភលើ“សិទ្ធិ”គ្នាមិនចែកសេចក្តីសុខដល់មនុស្សផងគ្នា,បានសុខទាំងអស់គ្នា,រស់នៅក្នុងសង្គមមនុស្សដូចគ្នាស្មើភាពគ្នា,មានសិទ្ធិសេរីភាពដូចគ្នាទាំងអសស់គ្នាដែលតាមព្រះពុទ្ធបំណង,ព្រះអង្គចង់ឲ្យមនុស្សនៅលើពិភពលោកទាំងមូលនេះទាំងអស់គ្នា,មានសេចក្តីសុខទាំងអស់គ្នាតែម៉្យាងប៉ុណ្ណោះ!នេះជាព្រះពុទ្ធបំណង!ៗតាមព្រះហឫទ័យរបស់ព្រះពុទ្ធព្រះអង្គចង់ឲ្យមនុស្សទាំងអស់គ្នា,នៅលើពិភពលោកទាំងមូលនេះ,ជាពិសេសអ្នកដែលមានទ្រព្យសម្បត្តិច្រើនៗមានបុណ្យសក្តិធំ,មានអំណាចខ្លាំងពូកែ,ទាំងអស់នោះបានពិចារណានូវ,អនិច្ចលក្ខណៈធម៌ខ្លះៗផងទៅ! កុំឲ្យលោភចិត្តនិងមោហាចិត្តវាអូសទាញវាបង្គាប់បញ្ជា!គឺឲ្យគិតថាវត្ថុទាំងនោះបុណ្យសក្តិទាំងអស់នោះ,វាមិនមានសារៈសំខាន់អ្វីទេ,មិនស្ថិតស្ថេរទេ,បន្តិចទៀតខ្លួនអាត្មាអញ,នឹងត្រូវស្លាប់ចោល, របស់អស់ទាំងនោះ,យ៉ាងពិតប្រាកដណាស់!ៗ ព្រះពុទ្ធចង់ឲ្យអ្នកទាំងអស់គ្នាគិតអញ្ចឹង!ហើយព្រះ

អង្គចង់ឲ្យគិតទៀតថាបំណាច់បានកើតមកជាមនុស្សដោយសារបុណ្យ រួចបុណ្យជួយផ្តល់ឲ្យមានទ្រព្យសម្បត្តិច្រើន,ឲ្យមានបុណ្យសក្តិធំៗ,រួចហើយៗទៅជាធ្វេសប្រហែសភ្លេចខ្លួននោះ!ព្រោះថាមានតែកំណើតជាមនុស្សនេះទេដែលជាកំណើតសំរាប់ កសាង,កសាងបុណ្យ(អំពើល្អ) ឬ(បាប)កសាងអំពើអ្វីបានតាមប្រាថ្នា!ៗ បានន័យថាៈមានតែអំពើល្អគឺបុណ្យនេះទេដែលអាចនាំបដិសន្ធិវិញ្ញាណរបស់សព្វសត្វទាំងអស់ឲកើតនៅស្ថានសួគ៌សុគតិភពបានៗ នែ!ព្រះពុទ្ធចង់ឲ្យមនុស្សទាំងអស់គ្នាគិតយ៉ាងនេះ,ហើយឲ្យធ្វើតាមយ៉ាងនេះ! ហើយដែលអាចគិតយ៉ាងនេះទៅបានល្អលុះណាតែដំកល់សតិស្មារតីឲ្យតាំងនៅមាំក្នុងអារម្មណ៍ឲ្យមូលតែមួយក្នុងចិត្តដែលហៅថាចំរើនសតិបដ្ឋានធម៌នោះឯងៗ ចប់សតិបដ្ឋានធម៌ទី១៕ ទី២-វេទនានុស្សនាសតិបដ្ឋាន ការដំកល់សតិស្មារតីពិចារណាវេទនាក្នុងវេទនា,តើសភាវៈអ្វីទៅដែលហៅថាៈវេទនា ?<u>ចម្លើយ</u>ៈ ការទទួលដឹងនូវអារម្មណ៍ឬការសោយនូវអារម្មណ៍ ហៅថាវេទនា,មាន៣យ៉ាងគឺៈ ទី១- បើការទទួលសោយនូវអារម្មណ៍ជា សុខ ហៅថា សុខវេទនា ៗ ទី២ - បើការទទួលសោយនូវអារម្មណ៍ជា ទុក្ខ ហៅថាទុក្ខវេទនាៗទី៣- បើការទទួលសោយនូវអារម្មណ៍មិនសុខមិនទុក្ខហៅថាមិនសុខមិនទុក្ខវេទនាឬហៅថា ឧបេក្ខាវេទនាៗ <u>សំនួរៈ</u>តើសភាវៈអ្វីទៅដែលពិចារណាឲ្យដឹងថានេះជាសុខ, នេះជាទុក្ខ,នោះ? <u>ចម្លើយ</u>ៈសភាវៈដែលពិចារណានោះគឺ"ចិត្ត"ៗចិត្តជាប្រធានជាធំជាងគេបង្អស់នៅក្នុងរូបកាយរបស់មនុស្សដែលកំពុងរស់នៅសព្វថ្ងៃហ្នឹង! ដូចមានព្រះពុទ្ធដីកាបញ្ជាក់ថាៈមនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយាជាដើម ប្រែៈចិត្តជាប្រធានក្នុងគ្រប់កិច្ចការទាំងពួងរបស់មនុស្ស ដូច្នេះក្នុងការពិចារណានូវសតិបដ្ឋានទាំងអស់,សុទ្ធតែមានចិត្តនេះជាប្រធានគ្រប់អន្លើ ឯសតិគ្រាន់តែជាជំនួយសំរាប់ជំរុញឬទាញឬទប់ចិត្តតែប៉ុណ្ណោះដែលហៅថាចេតសិក!ៗខ្ញុំលើកឧទាហរណ៍ឲ្យងាយស្តាប់

ងាយយល់ថាដូចជាសុខវេទនាដែលវាកំពុងសោយនូវអារម្មណ៍ជាសុខជាឥដ្ឋារម្មណ៍,អារម្មណ៍ជាទីពេញចិត្ត,គឺចិត្តដែលវាដឹងច្បាស់ថារូបនេះពេញជាស្អាត,ពេញជាល្អវាក៏គាប់ចិត្តណាស់!រួចចិត្តវាប្រកាន់ស្អិតថាៈកាយសម្បទារបស់អាត្មាអញនេះ! មានសម្ផស្សស្រស់ត្រកាល! សាច់ធាត់ទ្រលុកទន់ត្រជាក់ស្រឡូនរលូនសម្បុរស្បែកស្អាតផូរផង់សម៉ដ្ឋខៃអញ្ជឹងចិត្តវាជាប់ជំពាក់!ឆ្វាក់ចាក់ស្រេះ,ឈ្លក់,ងល់,ងប់ជ្រប់ងាប់ក្រឡានឹងសម្ផស្សនោះៗ,មិនអាចងាកចេញ,បានដោយងាយៗឡើយ!រួមផ្សំនឹងគ្រឹះស្ថានដ៏ធំស្កឹមស្កៃ,យានជំនិះតូចធំគ្រប់ប្រភេទ,ប្រើមិនស្កប់ទៅទៀត,អ្នកខ្លះមានគេបម្រើស្ដាំ-ឆ្វេងទៀត, បើដូច្នោះមានៈវាក៏រីកថ្លោសប៉ោងឡើងកាន់តែក្រាស់ឡើងៗទៅតាមនោះដែរ!។ឯចិត្តដែលវាកំពុងតែសោយអារម្មណ៍ជាសុខបែបនេះវាសោយមិនចេះស្កប់ឡើយ! វាចង់តែសោយឲ្យនៅតែជាសុខយ៉ាងហ្នឹង!ដ៏យូរអង្វែងរហូតដល់អាយុខែឯណោះ!។ នែ! កម្លាំងចិត្ត! ដែលវាសោយអារម្មណ៍ជាសុខហៅថាសុខវេទនាគឺវាសោយយ៉ាងហ្នឹង! សោយអញ្ជឹង!។ ប៉ុន្តែ!ប៉ុន្តែ! នែស្ដាប់ឲ្យច្បាស់! ប៉ុន្តែដល់មានសតិទៅចាប់ទៅទប់ចិត្តនោះជាប់! ហើយផ្ដល់ដំបូន្មានដ៏ល្អថាៈនែ!ចិត្ត!ចិត្តឯងត្រូវមានសម្បជញ្ញៈឡើងថា“របស់អស់ទាំងហ្នុង,វាមិនស្ថិតស្ថេរជាស្ថាពរទេវាតែងតែប្រែប្រួលជានិច្ចគ្រប់នាទីគ្រប់វិនាទី,ប្រសិនបើវាប្រែប្រួលដល់កំរិតរបស់វាគឺដល់ពេលដាច់ខ្យល់ស្លាប់ទៅនោះ!កាយសម្បទា ដែលស្រស់ទ្រលុកទ្រលន់ធាត់ត្រណលហ្នុងៗ! វានឹងប្រែទៅជារបស់ស្អុយ, ស្អុយរហូតដល់គេទុកដាក់ឲ្យនៅលើផ្ទះសម្បែងមិនកើតទៀតឯណោះ !។ ជាឧទាហរណ៍ដ៏ងាយស្រួលយល់ថាៈ ដូចជាលោកអ្នកខ្លះ, ដែលមានកូនសម្រានជាមួយរាល់យប់រាល់ថ្ងៃសំរ៉ានឱប!ឬថើបថែមទៀតផង! តែបើកូននោះអស់មានដង្ហើមចេញចូលគឺដាច់ខ្យល់ស្លាប់ហើយនោះ, នែ! ម្ដាយដែលធ្លាប់តែដេកជាមួយហ្នុង! មិនចាំបាច់និយាយដល់ទៅដេកជាមួយទៀតទេ,សូម្បីគ្រាន់

តែទៅជិតក៏មិនចង់ហ៊ានទៅជិតផង!។នេះគឺជាការសបញ្ជាក់ឲ្យឃើញ ច្បាស់ថារូបកាយរបស់មនុស្សយើងដែលហៅថា,បញ្ចក្ខន្ធ័,គឺខន្ធ័៥នេះ ជារបស់មិនមានខ្លឹមសារអ្វីទេ!, បើស្លាប់ហើយគ្មាននរណាគេត្រូវការអ្វី ទៀតទេ! គេតែងយកទៅបោះចោល , ឯព្រៃស្មសានជាចំណីរុយ, ឬចំ ណីដង្កូវឯណោះជាប្រាកដ, ប៉ុន្តែបើធ្វើយ៉ាងនេះទៅ វាខុសនឹងមនុស្ស ធម៌! ខុសនឹងសុជីវធម៌របស់មនុស្ស, ដូច្នេះគេក៏ដុតឬកប់ចោលទៅ!។ នៃ! យ៉ាងនេះ ឃើញថារូបកាយរបស់មនុស្សតែកាលណាស្លាប់ហើយ អន់ជាងដុំឈើទៅទៀត!។ អត្ថន័យត្រង់នេះចង់បង្ហាញអំពីកម្លាំង ឬក៏ ថាមពលនៃ“សតិ” វាមានឥទ្ធិពលអាចទប់អាចទាញចិត្ត ដែលវាកំពុង តែសោយនូវ សុខវេទនារម្មណ៍ ជាឥដ្ឋារម្មណ៍!, ឲ្យងាកចេញមករកនូវ សាមញ្ញលក្ខណធម៌គឺ,អនិច្ចំ,ទុក្ខំ,និងអនត្តា,វិញបាន។ ឯទ្រព្យសម្បត្តិ អ្វីផ្សេងៗឡានវីឡាមាស ពេជ្របុណ្យសក្តិច្រង៉េងច្រង៉ាងអ្វី, ក៏ដោយក៏ គ្មាននរណាម្នាក់អាចយកទៅជាមួយផងបានឡើយ! គឺត្រូវស្លាប់ចោល ទាំងអស់។ រួចសភាពបែបនេះមនុស្សនៅលើពិភពលោកនេះទាំងអស់ គ្មាននរណាមួយអាចគេចវេះចៀសវាងបានឡើយ,ពីព្រោះព្រះពុទ្ធទ្រង់ ពោលច្បាស់ណាស់ថាមរណន្តំ ហិ ជីវិតំ ប្រែៈជីវិតរបស់មនុស្សគ្រប់រូប សុទ្ធតែមានសេចក្តីស្លាប់នៅខាងចុងបំផុតគ្រប់ៗគ្នាព្រោះសេចក្តីស្លាប់ វាជាប់តាមជីវិតមក,តាំងពីថ្ងៃកើតមកម្ល៉េះ, គឺវាឋិតនៅជាមួយជីវិតរាល់ ថ្ងៃហ្នឹង,ប៉ុន្តែយើងមើលមិនដឹង,មានមនុស្សខ្លះ, ឮគេនិយាយពីសេចក្តី ស្លាប់មិនបានទេ!ខ្លាចណាស់! ប៉ុន្តែគាត់មិនបានដឹងថាសេចក្តីស្លាប់វា ឋិតជាប់នៅនឹងចុងច្រមុះ!របស់គាត់ហ្នឹងរាល់ថ្ងៃទេ! គឺសេចក្តីស្លាប់ វា ឋិតនៅជាប់នឹងច្រមុះហ្នុងឯង! ដូច្នេះ បានជាបណ្ឌិតលោកទូន្មាន ថាៈ បើទ្រព្យសម្បត្តិមាន, ត្រូវធ្វើទានកុំរុញរា, ព្រមទាំងសីលភាវនា, ទាន់- ខ្លួនជានៅធ្វើបាន។កុំធ្វេសកុំព្រងើយ,កុំកន្តើយមិនដឹងប្រាណ,ទាល់តែ រៀបចែកឋាន,នោះទើបបាន,និកស្តាយក្រោយ។ ស្លាប់ទៅតែម្នាក់ឯង,

កូនចៅតែងរៀបចំឲ្យ,ប្រវែងដីបណ្តោយ,តែ៤ហត្ថសម្រាប់កប់,ប្រសិន បើដុតវិញ,ឆ្អឹងនោះមិញ១កញ្ចប់,កូនចៅគេខ្ពើមស្អប់,មិនហ៊ានខ្ចប់ទុក លើផ្ទះ។ គេដុតបានឆ្អឹងមក, គេរកកោដិប្រញាប់ណាស់,ដាក់ឲ្យចេញ-ផុតពីផ្ទះ, យកទៅប្រោសចោលឯវត្ត។នែ!ឃើញទេ?គ្រាន់តែឆ្អឹងហ្នឹង គេមិនទុកផង,គេខ្ពើម,គេខ្លាចគេយកទៅចោលឲ្យឆ្ងាយ!ពីគេ!។ ព្រះសម្មាសម្ពុទ្ធសម្តែងថាៈ ភិក្ខុកាលណាពិចារណាឃើញដូច្នេះរឿយ !ៗ ស្មារតីរបស់ភិក្ខុនោះក៏រមែងតាំងឡើងប្រាកដថាវេទនាទាំងឡាយនេះ វាគ្រាន់តែជាវេទនាប៉ុណ្ណោះឯង! មិនមែនសត្វមិនមែនបុគ្គលមិនមែន ស្ត្រីមិនមែនបុរសឡើយ! ។ ការពិចារណាឃើញបែបនេះអាចកំណត់ ដើម្បីធ្វើឲ្យចំរើននូវប្រាជ្ញាចំរើននូវស្មារតី។ដោយអំណាចនៃការពិចារណាឃើញដូច្នេះចិត្តភិក្ខុនោះសោតក៏មិនជាប់ជំពាក់មិនអាស្រ័យនៅ ដោយតណ្ហានិងទិដ្ឋិផង!ទាំងមិនមានសេចក្តីប្រកៀកប្រកាន់នូវអ្វីតិច តួចក្នុងលោកនេះផង។ពាក្យថាលោកក្នុងទីនេះ!លោកសំដៅយករូប កាយរបស់យើងរាល់គ្នានេះឯង! <u>សតិបដ្ឋានទី៣</u>-ចិត្តានុបស្សនាសតិ-បដ្ឋាន ប្រែៈការផ្ចង់សតិគឺស្មារតីពិចារណានូវ“ចិត្ត”ក្នុងចិត្ត!។ ឥឡូវ! ដល់បញ្ហាចិត្តខ្លួនឯងម្តងវិញ!ព្រោះការដំកល់សតិស្មារតីពិចារណានូវ កាយក្តី,ពិចារណានូវវេទនាក្តី,ពិចារណានូវធម៌ក្តីគឺសុទ្ធតែចិត្តហ្នឹងឯង ជាអ្នកពិចារណា!ចុះឥឡូវដល់ចិត្តត្រូវពិចារណានូវចិត្តខ្លួនឯងវិញម្តង តើពិចារណាយ៉ាងម៉េចទៅ?បើចិត្តមិនមានរូបផងចិត្តមើលមិនឃើញ ផងតើតើពិចារណាយ៉ាងម៉េចទៅ?ហ្ហឺៈ!សំនួរនេះពិបាកឆ្លើយមែនហ្ន៎ ប៉ុន្តែណើ្ហយ!យើងគប្បីធ្វើការពិចារណាទៅតាមទស្សនៈពុទ្ធសាសនា ដែលមានព្រះពុទ្ធដីកាដូចតទៅនេះចុះ!ថាចិត្តមិនមានរូបពិតមែនចិត្ត មើលមិនឃើញមែន,ប៉ុន្តែយើងទាំងអស់គ្នាដឹងច្បាស់ណាស់ថា“មនុ-ស្ស!សុទ្ធតែមានចិត្ត”ព្រោះមនុស្ស! បើមិនមានចិត្តគឺវិញ្ញាណទេ!មិន អាចរស់បានទេ!។(តើមាននរណាយល់ថាមនុស្សអត់ចិត្តដែរឬទេ?)

ត្រង់ចំណុចនេះសូមជំរាបជូនយល់ឲ្យច្បាស់ថា“រូបកាយរបស់មនុស្ស យើងទាំងអស់នៅលើពិភពលោកនេះទាំងមូលសព្វថ្ងៃហ្នឹង,ដែលអាច មានចលនា រស់រវើកគ្រប់គ្នាទៅបានអាស្រ័យមកពីមានចិត្តគឺវិញ្ញាណ នេះឯង”, ប្រសិនបើមិនមានចិត្តទេ រូបកាយរបស់មនុស្សយើងគ្រប់គ្នា ហ្នឹងដូចគល់ឈើអញ្ចឹង!ជារបស់អត់ដឹងអ្វីទេ!, ប៉ុន្តែសភាវៈចិត្តនេះវា មានលក្ខណៈដ៏ពិសេសរបស់វាដែលស្តែងឡើងតាមចលនា រូបកាយ របស់មនុស្សយើងអាចឲ្យយើងដឹងបានថា“មនុស្សនេះចិត្តល្អ,មនុស្ស នេះចិត្តអាក្រក់”យ៉ាងនេះបានថែមទៀតឯណោះនែ!ចិត្តវាមិនមានរូប ពិតមែន,ប៉ុន្តែវាមានអានុភាពអាចឲ្យយើងដឹងយ៉ាងនេះបានចិត្តដែល អត់រូបនេះជាសភាវៈប៉ផ្លេកប៉ផ្លូចណាស់មានចលនារហ័សណាស់មិន ងាយស្ថិតនៅនឹងស្ងៀមបានទេ!,ព្រះពុទ្ធដីកាពោលថាៈ ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ ប្រែៈចិត្តជាសភាវៈញាប់ញ័រ, ឃ្លេងឃ្លោង, ពិបាក រក្សាពិបាកឃាត់ឃាំងណាស់!,មានតែព្រះអរិយៈទេ!ទើបលោកអាច ហាត់ពត់ចិត្ត,បង្វឹកចិត្តទូន្មានចិត្តមិនឲ្យមានពុតត្បុតធ្វើឲ្យជាចិត្តត្រង់ ដូចព្រួញបាន!ព្រះសម្ពុទ្ធទ្រង់បង្ហាញអំពីសភាវៈរបស់ចិត្តបន្ថែមទៀត ថាៈទុរង្គមំ ឯកចរំ អសរីរំ គុហាសយំ ប្រែថាៈចិត្តអត់សរីរៈនេះមានរូប កាយជាគុហាតែងត្រាច់ទៅតែម្នាក់ឯងទទួលអារម្មណ៍បានក្នុងទីឆ្ងាយ ៗណាស់ហើយត្រឡប់វិញក៏លឿនរហ័សណាស់!នៅលើពិភពលោក នេះពុំមានអ្វីលឿនរហ័សស្មើនឹងចិត្តនេះឡើយ!។ បើចង់ដឹងច្បាស់ពី ល្បឿនចិត្តដែលរហ័សនោះលោកអ្នកគិតបន្តិចថាៈបើលោកអ្នកមាន ផ្ទះនៅឯស្រុកខ្មែរ ឥឡូវពេលនេះលោកអ្នកកំពុងតែស្ថិតនៅសហរដ្ឋ អាមេរិក,រួចលោកអ្នកគ្រាន់តែនឹកគិតទៅគឺចិត្តរបស់លោកអ្នកវាបាន ឃើញផ្ទះរបស់លោកអ្នកនៅឯស្រុកខ្មែរឯណោះរួចបាត់ទៅហើយ!! នែ!ល្បឿនចិត្តវារហ័សអញ្ចឹង!នៅត្រង់ចំណុចនេះ ខ្ញុំសូមបញ្ជាក់អំពី សភាវៈនៃចិត្តដែលវាទទួលនូវអារម្មណ៍និងសម្ងំនៅក្នុងគុហារបស់វា

ដោយការប្រៀបធៀបបន្តិចទៅតាមទស្សនៈរបស់សម្តេចព្រះសង្ឃរាជ
ជួន-ណាតដែលសម្តេចពិចារណាតាមគន្លងពុទ្ធសាសនាសម្តេចប្រៀប
ប្រដូចចិត្តទៅនឹងសត្វពីងពាងថាៈធម្មតាសត្វពីងពាង,កាលណាវាស្ទង់
មើលស្ថានភាពភូមិសាស្រ្តដើមឈើណាមួយនៅហោជាងផ្ទះណាមួយ
ដែលវាអាចធ្វើសំបុកជាបណ្តោះអាសន្នរបស់វាបាន, វាក៏តាំងវាយខ្សែ
សំណាញ់របស់វាជុំវិញគ្រប់ទិស,ជារង្វង់មូលប៉ុន១ម៉ែត្រ, ឬកន្លះម៉ែត្រ
តាមដែលវាអាចលៃលកទៅបាន!, រួចវាវាយសរសៃសំណាញ់ប្រទាក់
ក្រឡាគ្នាយ៉ាងល្អិតជាបណ្តាញចាប់តាំងពីខាងរៀងរហូតចូលទៅដល់
រង្វង់មូលតូចចំត្រង់កណ្តាល,រួចហើយពីងពាងវាក្រាបសម្ងំស្ងៀមនៅទី
ចំត្រង់កណ្តាលនោះ, បើកាលណាមានសត្វល្អិតអ្វីផ្សេងៗដូចជារុយឬ
មូសជាដើមទៅប៉ះជាប់សំណាញ់របស់វានៅទិសខាងណា ?ពីងពាងវា
នឹងស្ទុះស្លែតទៅតាមខ្សែសំណាញ់ដែលញាក់នៅទិសនោះៗភ្លាម, រុយ
ឬសត្វល្អិតអ្វីៗនោះៗ ត្រូវបានពីងពាងវាខាំពាំនាំយកទៅសម្ងំស៊ីនៅទី
ចំកណ្តាលនោះជាប្រចាំ!, ហើយពីងពាង!វាក៏សម្ងំស្ងៀមនៅចាំជាបន្ត
ទៅទៀត។សេចក្តីនេះមានឧបមាយ៉ាងណា ?រីឯចិត្តរបស់មនុស្សយើង
ក៏មានឧបម៉េយ្យដូច្នោះដែរគឺចិត្តវាសម្ងំនៅក្នុងគុហាររបស់វាគឺ“បេះដូង
”នៅចំកណ្តាលរូបកាយរបស់យើងហ្នឹងឯង!=កាលណាមានអារម្មណ៍
ណាមួយទៅប៉ះតាមទ្វារកាយ,ចិត្តវាស្ទុះស្លែតទៅទទួលនៅទ្វារកាយៗ
បានដឹងថាឱ!ក្តៅឬត្រជាក់ឬទន់ឬរឹងយ៉ាងណាភ្លាមរួចហើយចិត្តវាទៅ
សម្ងំស្ងៀមនៅក្នុងគុហាររបស់វានោះវិញដដែល!។ =បើកាលណាមាន
អារម្មណ៍ណាមួយទៅប៉ះតាមទ្វារត្រចៀក,ចិត្តវាស្ទុះស្លែតទៅទទួលនៅ
ទ្វារត្រចៀក,ពិនិត្យដឹងថាឱ!សំឡេងពីរោះឬមិនពិរោះយ៉ាងណាភ្លាមៗ
= បើកាលណាមានអារម្មណ៍ណាមួយទៅប៉ះតាមទ្វារភ្នែក,ចិត្តវាក៏ស្ទុះ
ស្លែតទៅទទួលនៅទ្វារភ្នែកពិនិត្យឃើញថាឱ!រូបស្អាតឬមិនស្អាតយ៉ាង
ណាភ្លាម។= បើកាលណាមានអារម្មណ៍ណាមួយទៅប៉ះតាមទ្វារច្រមុះ

ចិត្តវាស្ទុះភ្លែតទៅទទួលនៅទ្វារច្រមុះពិនិត្យដឹងថាឱ!ក្លិនក្រអូបឬស្អុយ ឬឆ្អេះឬឆ្អាបយ៉ាងណាភ្លាមៗមួយរំពេច។តាមជីវ្ហាទ្វារ អណ្តាតក៏ដូចគ្នា ហើយចិត្តវាទៅសម្ងំនៅក្នុងគុហារបស់វា!គឺបេះដូងវិញដដែល!។ ដល់ពេលណាដែលចិត្តវាឈប់ទទួលអារម្មណ៍ពីទ្វារទាំងអស់,ហើយវាសម្ងំស្ងៀមនៅមួយកន្លែងក្នុងគុហារបស់វាគឺបេះដូងនោះ!នោះហើយដែលយើងគេសន្មត់ហៅថា"ដេកលក់"នោះ!តែបើតាមការពិតគឺចិត្តវាឈប់ទទួលអារម្មណ៍ពីទ្វារទាំងអស់នោះទេដើម្បីបញ្ជាក់ឲ្យច្បាស់ពីរឿងនេះ យើងឲ្យនរណាម្នាក់!ឬវត្ថុអ្វីមួយទៅប៉ះរូបដែលដេកស្លកជាគុហារបស់ចិត្តនោះ,ប៉ះឲ្យខ្លាំងទៅធ្វើឲ្យវារញ្ជួយទៅដល់ចិត្តចិត្តវានឹងស្ទុះភ្លែតទៅទទួលអារម្មណ៍វិញភ្លាមមួយរំពេចអត់យូរទេ,រួចហ្នឹងហើយ!ដែលយើងគេកំណត់ថា"ភ្ញាក់ពីដំណេក"នោះ!តាមទស្សនរបស់ព្រះពុទ្ធសាសនា ថាចិត្តវាឋិតនៅក្នុងបេះដូងរបស់មនុស្សយើងដូច្នេះឯងហើយចិត្តដែលវាទទួលនូវអារម្មណ៍ទាំងឡាយផ្សេងៗ! គឺវាទទួលតាមរបៀបនេះឯង! ដោយចិត្តជាសភាវៈលំបាកហ្វឹកហាត់, លំបាកហាត់ពត់, លំបាកឃាត់ឃាំងឲ្យតាំងនៅស្ងៀមក្នុងអារម្មណ៍ឲ្យមូលតែមួយបានដូច្នេះទើបបានជាព្រះសម្មុទ្ធទ្រង់ទូន្មាន"ម្នាលភិក្ខុឬយោគាវចរទាំងឡាយ! បើអ្នកដឹងថាចិត្តវាពិបាកគ្រប់គ្រងយ៉ាងនេះហើយអ្នកគប្បីខំប្រឹងព្យាយាមហើយព្យាយាមទៀតហាត់ពត់ចិត្តបង្វឹកចិត្តបន្តិចម្តង!ឲ្យបានរឿយៗជាប្រចាំទៅ!យូរទៅអ្នកនឹងថ្នឹក!អ្នកនឹងបានសម្រេចដូចបំណងមិនខានឡើយ វិធី ឬមធ្យោបាយ!សម្រាប់អប់រំបង្វឹកចិត្តនោះព្រះសម្មុទ្ធទូន្មានឲ្យបង្វឹកទៅតាមលក្ខណៈបដិច្ចសមុប្បាទធម៌និងអានាបានស្សតិធម៌ជាដើម!។ =ទ្រង់ឲ្យពិចារណាថាៈបើចិត្តប្រកបដោយរាគៈត្រូវដឹងឲ្យច្បាស់ថាចិត្តរបស់អាត្មាអញប្រកបដោយរាគៈគឺ!តម្រេកត្រេកត្រអាលក្នុងអារម្មណ៍ផ្សេងៗដែលជាលោភមូលចិត្ត,បើចិត្តប្រាសចាករាគៈ ក៏ត្រូវដឹងច្បាស់ថាចិត្តរបស់អាត្មាអញប្រាសចាករាគៈហើយ។ = ទ្រង់ឲ្យពិចារណាថាៈ

បើចិត្តប្រកបដោយមោហៈត្រូវដឹងច្បាស់ថាចិត្តរបស់អាត្មាអញប្រកបដោយមោហៈ,បើចិត្តប្រាសចាកមោហៈក៏ត្រូវដឹងច្បាស់ថាចិត្តរបស់អាត្មាអញប្រាសចាកមោហៈហើយ!។=ទ្រង់ឲ្យខំប្រឹងព្យាយាមបន្ថែមការពិចារណាទៀតថាៈទោះបីចិត្តបានដំកល់មាំក៏ត្រូវដឹងថាចិត្តរបស់អាត្មាអញបានដំកល់មាំហើយ,ចិត្តដែលដំកល់មាំបានដល់ចិត្តដែលប្រព្រឹត្តទៅក្នុងឧបចារសមាធិនិងអប្បនាសមាធិ។និយាយដល់ត្រង់នេះក៏មានសេចក្ដីជ្រាលជ្រៅល្អិតល្អន់បន្តិចដែរព្រោះចិត្តប្រកបដោយឧបចារសមាធិនិងអប្បនាសមាធិនេះជាចិត្តរបស់លោកអ្នកប្រព្រឹត្តចូលជាសមាធិកនៃឈានសមាបត្តិហើយដូច្នេះ,ដើម្បីបញ្ចប់សុំធ្វើសេចក្ដីបំប្រួញឲ្យរាក់ឡើងវិញ!ព្រះសម្ពុទ្ធទ្រង់ត្រាស់ថាភិក្ខុបើកាលណាបានពិចារណាឃើញដូច្នេះហើយស្មារតីរបស់ភិក្ខុនោះក៏នឹងតាំងឡើងប្រាកដថា“ចិត្តនេះវាគ្រាន់តែជាចិត្តប៉ុណ្ណោះឯង,មិនមែនសត្វមិនមែនបុគ្គល,មិនមែនបុរសមិនមែនស្ត្រីឡើយ”ដែលកំណត់យ៉ាងនេះដើម្បីឲ្យចំរើននូវប្រាជ្ញាឲ្យមានស្មារតីរឹងប៉ឹងមាំមួនឡើង,ដោយអំណាចនៃការពិចារណាឃើញដូច្នេះ!ចិត្តរបស់ភិក្ខុនោះ! ក៏នឹងមិនជាប់ជំពាក់មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង,ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីតិចតួចក្នុងលោកគឺរូបកាយនេះផង។ នែ! ដែលព្រះសម្មាសម្ពុទ្ធឲ្យលើកឡើងនូវចិត្តពិចារណានូវចិត្តនោះគឺព្រះអង្គឲ្យពិចារណាដូច្នេះឯង។ឥឡូវ សតិបដ្ឋានទី៣-ចិត្តានុបស្សនាសតិបដ្ឋាន បញ្ចប់ត្រឹមតែប៉ុណ្ណេះឯង ឯវំ ៕

= <u>សតិបដ្ឋានទី៤</u>-ធម្មានុបស្សនាសតិដ្ឋាន ការដំកល់សតិពិចារណានូវធម៌ក្នុងធម៌, ធម៌ក្នុងទីនេះបណ្ឌិតលោកសំដៅយក“នីវរណធម៌” ដែលប្រែថាៈធម៌ជាគ្រឿងរារាំងស្ទាក់ដំណើរកុសលចិត្តមិនឲ្យកើតឡើងបាន នីវរណធម៌មាន៥យ៉ាងគឺទី១-កាមច្ឆន្ទៈ ចំណង់ក្នុងកាមឬចំណង់ដែលកើតឡើងដោយអំណាចនៃកាម!។ ទី២-ព្យាបាទៈ ធម្មជាតិដែលញ៉ាំងប្រយោជន៍ឬសេចក្ដីសុខរបស់អ្នកដទៃឲ្យវិនាស! ។ ទី៣-ថីនមិទ្ធៈ ចិត្ត

ដែលរុញរា,ខ្ជិលច្រអូស, ឬងោកងុយ។ ទី៤-ឧទ្ធច្ចកុក្កុច្ចៈចិត្តដែលរាយមាយ,អណ្តែតអណ្តូងទៅរកអារម្មណ៍ផ្សេងៗ។ ទី៥- វិចិកិច្ឆា ចិត្តដែលសង្ស័យស្ទាក់ស្ទើរមិនដាច់ស្រេច!គ្រាន់តែប្រែនីវរណធម៌ទៅយើងនឹងបានឃើញច្បាស់ថាវាស្មុគ្រស្មាញណាស់!, គឺនីវរណធម៌នេះវារាំងដំណើរចិត្តជាកុសលល្អហ្នឹងជុំជិតល្ងិតឈឹងមិនឲ្យកើតឡើងបានឡើយប៉ុន្តែដោយសារកម្លាំងសហជាតធម៌!គឺ“សតិ” ជាជំនួយដ៏រឹងមាំណាស់ទើបធ្វើឲ្យចិត្តមានពន្លឺរស្មីឡើងបាន!។ ឯនីវរណធម៌ទាំង៥នេះបណ្ឌិតលោកសង្កត់ធ្ងន់ទៅលើកាមច្ឆន្ទៈខ្លាំងជាងគេ, ច្រើនជាងគេ, ថាវាមានឥទ្ធិពលខ្លាំងជាងគេដោយលោកបញ្ជាក់អត្ថន័យៈ កាមច្ឆន្ទៈជាប្រធានជាមេគេ,ព្រោះវាមានឆន្ទៈមុះមុតណាស់, វាចាក់ជ្រៅដោតជាប់ទៅក្នុងកាមតណ្ហាដែលជាគ្រឿងចងក្រៀកសព្វសត្វឲ្យលិចលង់,លិចអណ្តែតៗនៅក្នុងមហាសមុទ្រវដ្តសង្សារដ៏ធំធេងនេះមិនមានទីបំផុតឡើយ!។ បើនិយាយឲ្យងាយស្រួលស្តាប់ជាងនេះកាមច្ឆន្ទៈជាចិត្តដែលជាប់ស្អិតដែលញ៉ាមញៀន!ឬដែលដេកត្រាំនៅក្នុងកាម,រួចកាមនេះវាក៏ជាចំណីប្រចាំជីវិតរបស់ចិត្ត,ត្រង់នេះចង់តែនិយាយថាៈចិត្តបើមិនមានកាមទេ!ហាក់ដូចជាមិនអាចតាំងនៅបានឡើយ!។(នេះនិយាយចំពោះតែចិត្តរបស់បុថុជ្ជនទេ)។ បណ្ឌិតលោកប្រៀបប្រដូចចិត្ត និងកាម នេះថាដូចជាត្រីនិងទឹក,ឲ្យពិចារណាមើលថាធម្មតាត្រីជាសត្វដែលរស់នៅតែក្នុងទឹក!បើកាលណាយើងចាប់លើកវាស្រង់ពីក្នុងទឹកយមមកដាក់នៅលើគោក, ត្រីវាមិនដែលនៅស្ងៀមទេវាតែងតែលោតកន្ត្រោង,បំរះននាលទៅរកទឹកវិញជាដរាប,បើមិនដូច្នោះទេ,ត្រីវាលោតបម្រះ,ននាលទាល់តែស្លាប់ខ្លួន!។ ផ្ទុយទៅវិញ!ប្រសិនបើវាបម្រះបានចូលទៅក្នុងទឹកវិញនោះ!ត្រីវានឹងហែលផ្លូចចុះផ្លូចឡើងៗដោយក្តីសប្បាយរីករាយបំផុត!សេចក្តីនេះមានឧបមាយ៉ាងណាមិញ?ឯចិត្តរបស់មនុស្សបុថុជ្ជនយើងក៏មានឧបមេយ្យដូច្នោះដែរ។ កាមនេះវាជាចំណីជាចំណូលរបស់ចិត្តឬ

នឹងថាជាលំនៅរបស់ចិត្តដូច្នេះក៏សឹងតែថាបាន! ព្រោះចិត្តវាស្អិតរមួតណាស់ជាមួយនឹងកាមនេះទាំងវត្ថុកាមទាំងកិលេសកាមចិត្តជាសភាវៈញាប់ញ័រណាស់!,របិលរប៉ូចណាស់, មិនងាយតាំងនៅស្ងៀមនឹងមួយកន្លែងបានទេ។ដើម្បីពិសោធន៍ឲ្យឃើញច្បាស់នូវចរន្តឬចលនារបស់ចិត្តនោះ! យើងត្រូវដកចិត្តរបស់យើងយកទៅធ្វើការពិចារណានូវធម៌អាណាបានស្សតិ តាមរយៈខ្យល់ដង្ហើមចេញចូលរបស់យើងទើបដឹងឯវិធីធ្វើគឺយើងទៅរកកន្លែងណាមួយដ៏ស្ងាត់,យើងអង្គុយពែនព្នែនរួចយកជើងស្តាំដាក់លើជើងឆ្វេង,ផ្ងាបាតដៃស្តាំដាក់លើបាតដៃឆ្វេង,នៅលើព្នែនរបស់យើង,តម្រង់ដងខ្លួនឲ្យត្រង់ផ្ទៃមុខឆ្ពោះត្រង់ទៅមុខកុំឱនឈ្ងោកមុខ,ខ្នងកុំផ្អែកនឹងវត្ថុអ្វីមួយ, ខាំធ្មេញឲ្យជាប់យកអណ្តាតទល់នឹងជើងធ្មេញខាងលើ,ធ្មិចភ្នែកហើយប្រមូលចិត្តដាក់ក្នុងទ្រូងជាដំបូងត្រូវដកដង្ហើមឲ្យវែងៗ=បើយើងដកដង្ហើមចេញវែងឲ្យចិត្តវាដឹងច្បាស់ថាខ្យល់ដង្ហើមចេញវែង=បើយើងដកដង្ហើមចូលវែងឲ្យចិត្តវាដឹងច្បាស់ថាខ្យល់ដង្ហើមចូលវែង,= បើយើងដកដង្ហើមចេញខ្លីឲ្យចិត្តវាដឹងច្បាស់ថាខ្យល់ដង្ហើមចេញខ្លី,=បើយើងដកដង្ហើមចូលខ្លីឲ្យចិត្តវាដឹងច្បាស់ថាខ្យល់ដង្ហើមចូលខ្លី!,យ៉ាងនេះជាដើម! គឺឲ្យចិត្តវាតោងនូវចលនាខ្យល់ដង្ហើមចេញ-ចូលរបស់យើងឲ្យជាប់គ្រប់ខណៈគ្រប់ចលនាអញ្ចឹង!!។ រឿងនេះប្រសិនបើយើងមិនធ្លាប់បានបង្វឹកចិត្តរបៀបនេះពីមុនមកទេ! រួចយើងទើបតែចាប់ផ្តើមធ្វើជាលើកដំបូងតែម្តងចិត្តនេះវាស្ថិតនៅតាមចលនាដង្ហើមចូល-ចេញរបស់យើងបានយ៉ាងយូរត្រឹមដង្ហើមចេញចូល៤ឬ៥ដងប៉ុណ្ណោះ,វានឹងស្ទុះចេញទៅរកអារម្មណ៍ផ្សេងៗវិញមិនខាន! ជាពិសេសគឺទៅរកកាម នោះឯង!ដែលដូចជាទឹក របស់ត្រី! អញ្ចឹង!។ នែ!ចិត្តវាប៉ផ្លេកប៉ផ្លូចពិបាកគ្រប់គ្រងអញ្ចឹងចំពោះរឿងនេះលុះណាតែលោកអ្នកធ្វើការពិសោធន៍ខ្លួនឯងផ្ទាល់,ទើបដឹងច្បាស់ថាចិត្តរបស់ខ្លួនយើងនេះវាយ៉ាងម៉េច!កាមច្ឆន្ទះចិត្តដែលជាប់ស្អិតនឹងកាមនេះបណ្តិត

លោកពោលថាមិនមាននរជនណាអាចលះបង់!ឬដកចិត្តនេះចេញពីកាមបានដោយងាយៗនោះឡើយ,ប៉ុន្តែប្រសិនបើនរជនណាលះបង់បានឬដកចិត្តនេះចេញពីកាមបានវិញនោះ!ជាការប្រសើរបំផុតដែលបណ្ឌិតលោកប្រសិទ្ធិនាមឲ្យនរជននោះថាជា“អរិយជន”។ ឯនីវរណធម៌៤ទៀតគឺព្យាបាទៈថីនមិទ្ធៈឧទ្ធច្ចៈ កុក្កុច្ចៈនិងវិចិកិច្ឆាក៏ហាក់ដូចជារលត់ទៅឯងៗដោយមិនចាំបាច់ខំប្រឹងលះផងឲ្យតែលះបង់ កាមច្ឆន្ទៈនេះបានជ្រះស្រឡះហើយ។ ឧទាហរណ៍ៈដូចជាឧទ្ធច្ចកុក្កុច្ចៈប្រែៈចិត្តរាយមាយ,ចិត្តអណ្តែតអណ្តូង,រួចចិត្តដែលវាអណ្តែតអណ្តូងទៅហ្នុង! តើវាអណ្តែតអណ្តូងទៅរកអ្វី? មិនអណ្តែតអណ្តូងទៅរកកាម?ចុះបើកាមច្ឆន្ទៈយើងលះបង់បានហើយតើចិត្តអណ្តែតអណ្តូងទៅរកអ្វីទៀត?។ដូច្នេះបានជាបណ្ឌិតលោកពោលថាៈបើបុគ្គលណាលះបង់បានឬកាត់ផ្តាច់នូវនីវរណកាមច្ឆន្ទៈនេះបានដាច់ជ្រះស្រឡះហើយ, នីវរណៈធម៌ទាំង៤យ៉ាងទៀតនោះក៏ដូចជារលត់ទៅផងដែរ!។ ឯមធ្យោបាយសំរាប់លះនូវកាមច្ឆន្ទនីវរណៈនេះព្រះពុទ្ធទ្រង់ទូន្មានថាត្រូវមានយោនិសោមនសិការៈក្នុងអសុភនិមិត្តគឺតាំងចិត្តកំណត់នូវអារម្មណ៍ថាមិនល្អក្នុងរូបធាតុនានាត្រូវធ្វើទុកក្នុងចិត្តឲ្យច្បាស់ដាច់ខាត!ដោយឧបាយនៃប្រាជ្ញាក្នុងរបស់ដែលមិនទៀងថាៈពិតជាមិនទៀង!, ក្នុងរបស់ដែលជាទុក្ខថាៈពិតជាទុក្ខ!,ក្នុងរបស់ដែលមិនមែនជារបស់ខ្លួន! ថាៈពិតជាមិនជារបស់ខ្លួនមែន!,បើពិចារណាបែបនេះឲ្យបានរឿយៗទៅ,យូរទៅអ្នកនឹងថ្មឹក។ព្រះសម្ពុទ្ធទ្រង់បញ្ជាក់ថាៈម្នាលភិក្ខុទាំងឡាយ!ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាឲ្យបានរឿយៗក្នុងអសុភនិមិត្តបែបនេះ! ជាហេតុបច្ច័យនាំកាមច្ឆន្ទៈដែលមិនទាន់កើតឡើង, មិនឲ្យកើតឡើងបានបើទុកជាកើតឡើងហើយ! ក៏អាចលះបង់បានងាយ!។ ព្រះសម្ពុទ្ធទ្រង់ត្រាស់សំដែងនូវព្រះធម៌ដែលប្រព្រឹត្តទៅដើម្បីលះនូវកាមច្ឆន្ទៈបានដែរមាន៦យ៉ាងទៀត១-អសុភនិមិត្តឧគ្គហៈ ការរៀននូវអសុភនិមិត្ត។ ក៏គឺ

និមិត្តថាមិនស្អាតៗហ្នឹង! ២-អសុភភាវនានុយោគៈការប្រកបព្យាយាមរឿយៗក្នុងអសុភភាវនា!។ ទី៣-ឥន្ទ្រិយេសុគុត្តទ្វារតា ភាពជាអ្នកមានទ្វារគ្រប់គ្រងល្អហើយក្នុងឥន្ទ្រីយ៍ទាំងឡាយជាពិសេសចក្ខុន្ទ្រីយ៍គឺភ្នែកនេះឯង!។ ៤-ភោជនេមត្តញ្ញុតា ភាពជាអ្នកដឹងប្រមាណក្នុងភោជន។ ៥-កល្យាណមិត្តតា ភាពជាអ្នកមានមិត្តល្អ! ។ ៦-សប្បាយកថា គឺការនិយាយឬស្តាប់នូវពាក្យដែលនាំឲ្យសប្បាយ,ជាធម្មសប្បាយ(វៀរចាកតិរច្ឆានកថា)។គុណធម៌ទាំង៦យ៉ាងនេះខ្ញុំគ្រាន់តែលើកជាមាតិកាមកតែប៉ុណ្ណោះ!ពុំបានធ្វើអត្ថាធិប្បាយអីទេ! សូមលោកអ្នកសប្បុរសទាំងឡាយមេត្តាធ្វើការពិចារណាដោយខ្លួនឯងផ្ទាល់ផង។= សាធុសប្បុរសទាំងឡាយ!ព្រះធម៌ទេសនាស្តីអំពីសតិបដ្ឋានសូត្រ ទាំង៤ប្រការដែលខ្ញុំបានធ្វើការពិពណ៌នាមកតាមបញ្ញាដ៏តិចតួចស្តួចស្តើងរបស់ខ្ញុំនេះគឺដោយយោលទៅតាមឧត្តមគតិជាគោលទស្សនៈរបស់ព្រះគ្រូសិរីសោ-ភណ្ឌ័ គឹម-តូ វត្តឧណ្ណាលោមផងដែរ!ហើយក៏ជាលើកទី១នៃ ការរៀនសរសេរអត្ថបទធម៌របស់ខ្ញុំ!ហើយឥឡូវសូមបញ្ចប់ង្ខេបប៉ុណ្ណោះខ្ញុំសូមអធ្យាស្រ័យអំពីសំណាក់អស់លោកអ្នកជាកវីបណ្ឌិតអត្ថកោវិទ.ដែលជាពហុស្សូតទាំងឡាយ!មេត្តាអភ័យដោយមេត្រីនូវរាល់កំហុសឆ្គងទាំងឡាយណាដែលអាចមានដោយអចេតនាផងចុះ ៕

ដោយភិក្ខុ **ខែម-អ៊ុន** ឬ **សំអៀន “អភិញ្ញានសីលោ”**

<u>**ឯវំ ចប់ហោង**</u>!